

2

មេរៀនទី២: រឿងដើមឈើ២ដើម

A Tale of Two Trees

3



មេរៀនទី៣: បញ្ហាខាងផ្លូវច្បាប់ដ៏ធំនៅក្នុងព្រះគម្ពីរ

The Greatest Problem in the Bible

មេរៀនទី៤

4



សេចក្តីតំរូវតែមួយគត់សំរាប់ស្ថានសួគ៌

The Only Requirement for Heaven

5



មេរៀនទី៥ សេក្តីសង្គ្រោះ: អតីតកាល បច្ចុប្បន្នកាល និង អនាគតកាល

Salvation: Past, Present, and Future

មេរៀនទី៦

ព្រះវិញ្ញាណបរិសុទ្ធ



ភ្នាក់ងារនៅក្នុងសប្បុរិសកម្ម

6

The Holy Spirit:

The Agent in Sanctification

ទំនាក់ទំនងជាសាវក: 7

លក្ខណ:សំគាល់ជាអ្នកគ្រីស្ទាន



មេរៀនទី៧

Discipleship:

The Christian’s Identity

មេរៀនទី៨: ជីវិតរបស់អ្នកគ្រីស្ទាន

The Christian’s Life 8




មេរៀនទី៩: បេសកកម្មរបស់អ្នកគ្រីស្ទាន

The Christian’s Commission 9



# ហេតុអ្វីសិក្សាព្រះគម្ពីរ?

## Why Study the Bible?



មេរៀនទី១

1

និពន្ធជាភាសាអង់គ្លេសដោយ លោកបាស្ទ័របណ្ឌិត ហោវើឌ ហ្វលិន

និពន្ធ រៀបចំនិងកែសំរួលជាភាសាខ្មែរដោយ លោកបាស្ទ័របណ្ឌិត ជេម្ស ច័ន្ទឡា ដុក

សម្ព័នអន្តរជាតិអាដវេនទីស្ទខ្មែរ

**Cambodian Adventist International**

This lesson study is published by Cambodian Adventist International (CAI) with generous helps and supports of the Pacific Union Conference of Seventh-day Adventists for a purpose of evangelistic outreach.

Please contact us first before making any photocopy of this material.


**CAI**

**2210 East Poinsettia Street**

**Long Beach, CA 90805-2630**

Or email us at:

*thenewlight.cai@gmail.com*


The New Light Podcast ពន្លឺថ្មី


Unless otherwise noted, all scripture quotations are from The Bible in Khmer, published by United Bible Societies.

© 2014 by Cambodian Adventist International (CAI).

All rights reserved.



2210 E. Poinsettia St., Long Beach, CA 90805-2630

Published in the United States of America


# សម្លេងបងខាស្ត

# “ពន្លឺថ្មី”



Pastor James Dok, Speaker

***ផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូវនៃ***

***តំបន់រដ្ឋកាលីហ្វ័រនីញ៉ាប៉ែកខាងត្បូង សហរដ្ឋអាមេរិក***

បើលោកអ្នកមានលទ្ធភាពក្នុងការប្រើប្រាស់កុំព្យូទ័រ អ៊ិនធើណែត ឬ ស្មាតហ្វូន សូមឡុគ្គអ៊ិន (log in) *www.linguaspirita.net* ហើយសូមចុចលើពាក្យ **Khmer** លោកអ្នកអាចទទួលស្តាប់នូវដំណឹងល្អអំពីព្រះយេស៊ូវតាមរយៈលោកប៉ាស្ទ័រ ដេម្ស ច័ន្ទឡា ដុក។ ហើយបើលោកអ្នកមានបំណងចង់:

- សិក្សារព្រះគម្ពីរ
- ដឹងពីសេចក្តីសង្គ្រោះរបស់ព្រះយេស៊ូវ និងជីវិតរបស់ទ្រង់
- បានសេចក្តីសង្ឃឹមនៅក្នុងជីវិតដែលមានព្រះ ឬ
- ជួយជាជំនួយ ខាងថវិការ ពេលវេលា និង វិជ្ជាជីវៈ

សូមអ៊ីម៉េល :

*thenewlight.cai@gmail.com*

ឬ សរសេរសំបុត្រទៅកាន់:


**Cambodian Adventist International (CAI)**

**2210 E. Poinsettia St.**

**Long Beach, CA 90805-2630**



៤) **ចំពូកវែងនិងខ្លីជាងគេនៅក្នុងព្រះគម្ពីរ:** ជំពូកដែលវែងជាងគេបង្អស់នៅក្នុងព្រះគម្ពីរ គឺនៅក្នុងសៀវភៅទំនុកដំកើង ជំពូក១១៩ ដែលមានខទាំងអស់ចំនួន១៧៦។ ឯជំពូកដែលខ្លីជាងគេ ក៏នៅក្នុងសៀវភៅ ទំនុកដំកើងដដែល ជំពូក១១៧ដែលមានខចំនួនតែ២ប៉ុណ្ណោះ។ ហើយជំពូក១១៧ នេះគឺជាជំពូកមួយដែលនៅចំពាក់កណ្តាលព្រះគម្ពីរទៀតផង។

សៀវភៅដែលវែងជាងគេនៅក្នុងព្រះគម្ពីរក៏ជាសៀវភៅទំនុកដំកើងដែរ ដែលមាន១៥០ជំពូកនិង៤៣៧៤ពាក្យ (គិតជាជាភាសាអង់គ្លេស)។ ចំណែកសៀវភៅដែលខ្លីជាងគេ គឺសៀវភៅយ៉ូហានទី៣ មានជំពូកតែ១និងពាក្យចំនួនតែ២៩៩ ប៉ុណ្ណោះ(គិតជាជាភាសាអង់គ្លេស)។

ខដែលវែងជាងគេ គឺនៅក្នុងសៀវភៅ នាងអេសធើរ ជំពូក៨ខ៩ដែលមានចំនួន៩០ពាក្យ (គិតជាជាភាសាអង់គ្លេស)។ ឯខដែលខ្លីជាងគេបង្អស់គឺនៅក្នុងសៀវភៅយ៉ូហាន ជំពូក១១ខ៣៥ ដែលមានតែពីរពាក្យប៉ុណ្ណោះ "Jesus wept/ ព្រះយេស៊ូវក៏ទ្រង់ព្រះកន្សែង។"




៥) **ព្រះគម្ពីរត្រូវបានទទួលអះអាងថាជាព្រះបន្ទូលរបស់ព្រះ:** មានសៀវភៅដែលបានចងក្រងឡើងជាច្រើនក្បាលដោយមេសាសនាធំៗនិងល្បីៗ តែគ្មានសៀវភៅណាមួយដែលអះអាងថាជាព្រះបន្ទូលរបស់ព្រះឡើយ គឺមានតែព្រះគម្ពីរប៉ុណ្ណោះ។ ចំពោះអ្នកដែលជឿថាព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ ក៏ជឿថាព្រះបានបណ្តាលឲ្យមនុស្សចងក្រងព្រះគម្ពីរឡើងសំរាប់ជាជំនួយដ៏មានប្រយោជន៍ដល់មនុស្សលោកយើងផងដែរ។ ព្រះគម្ពីរចែងថា មាន៣០០០ពាក្យដែលនិយាយថា: "Thus saith the Lord/ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា"។ ពាក្យទាំងនេះ ភាគច្រើនគេបានជឿថាគឺជាពាក្យដែលបានដកស្រង់ចេញពីព្រះបន្ទូលរបស់ព្រះយេស៊ូវពិតៗ។

៦) **ព្រះគម្ពីរគឺជាប្រវត្តិសាស្ត្រដ៏ពិតនិងមានកំណត់ត្រាត្រឹមត្រូវ:** មានអ្នកប្រវត្តវិទូរជាច្រើនដែលបានសរសេរពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងគម្ពីរសញ្ញាថ្មី នៅទន្ទឹមនឹងពេលដែលព្រះគម្ពីរបានត្រូវចងក្រងឡើង។ ក្នុងចំណោមប្រវត្តវិទូរទាំងអស់នោះ លោកយោសីហ្វើសដែលជាអ្នកល្បីល្បាញជាងគេ ហើយលោកក៏ជាជនជាតិអ៊ីស្រាអែលផងដែរ។ បន្ទាប់មកលោកប្រវត្តវិទូរតាក់ស៊ីតឹស ដែលជាជនជាតិរ៉ូម៉ាំង ដែលល្បីថាជាប្រវត្តិវិទូរចងក្រងតែការពិត ក៏បានទទួលស្គាល់ថា ព្រះគម្ពីរគឺពិតជាប្រវត្តិសាស្ត្រដ៏ពិតៗមែន។ បានសេចក្តីថា គេអាចទទួលយកនូវការចងក្រងរបស់លោកទាំងពីរ និងប្រវត្តវិទូរមួយចំនួនទៀតជាផ្លូវការបាន។

មានការស្រាវជ្រាវជាប្រវត្តិសាស្ត្រថ្មីៗជាច្រើនទៀតដែលបញ្ជាក់ពីព្រឹត្តិការណ៍នៅក្នុងព្រះគម្ពីរ ដែលបានកើតឡើងពិតមែនដូចជាលោកប្រវត្តវិទូរ ម៉ែរល់ អង់ហ្គើរ អ្នកនិពន្ធវចនានុក្រមព្រះគម្ពីរបានសរសេរថា "អ្នកបូរាណវិទូរនៃគម្ពីរសញ្ញាចាស់ បានរុករកឃើញនូវទីក្រុងបូរាណៗ និងបុគ្គលសំខាន់ៗពីបូរាណដែលបានបញ្ជាក់ប្រាប់យើងនូវលក្ខណៈសំខាន់ៗជាច្រើន នៅក្នុងការយល់ដឹងនិងរៀនសូត្រពីសង្គមសាស្ត្រនិងប្រវត្តិសាស្ត្រនៅក្នុងជំនាន់នោះ។

*-តទៅទំព័រទី១២*



# ហេតុអ្វីសិក្សារព្រះគម្ពីរ?
## មេរៀនទី១

## សេចក្តីផ្តើម

### A. សំនួរនិងចំលើយដ៏ពិបាកបំផុត

មុនពេលយើងចាប់ផ្តើមសិក្សារព្រះគម្ពីរ យើងគួរដឹងថា តើហេតុអ្វីយើងមានចំណង់នៅក្នុងការសិក្សារនេះជាមុនសិន។ យើងសិក្សារព្រះគម្ពីរពីព្រោះព្រះគម្ពីរឆ្លើយនូវសំនួរទាំងឡាយណាដែលមនុស្សយើងមានចំងល់។



ព្រោះយើងដឹងថា គឺមានតែមនុស្សយើងទេ ដែលជាសត្វលោក ចេះសាកសួរពីអត្ថន័យនៅក្នុងការរស់នៅមានជីវិតរបស់យើង។ មានតែមនុស្សយើងទេ ដែលចេះសួរថា តើយើងមានកំណើតកើតពីណាមក? មានតែមនុស្សយើងទេដែលមានចំងល់ថា តើហេតុអ្វីបានជាគេមានជីវិតរស់នៅលើផែនដីនេះ ហើយតើដើម្បីអ្វី? ទីបញ្ចប់ គឺមានតែមនុស្សយើងទេដែលចង់ដឹងថា តើនៅពេលដែលយើងស្លាប់ទៅ ជីវិត ព្រលឹងវិញ្ញាណ និងការចងចាំរបស់យើង នឹងត្រូវទៅកាន់ទីកន្លែងណាហើយក្លាយទៅជាយ៉ាងដូចម្តេច?



សំនួរទាំងអស់នេះត្រូវគេចាត់ទុកនៅក្នុងក្រុមពិសេសមួយដែលយើងហៅថា ទស្សនវិជ្ជា ពីព្រោះវាជាសំនួរដែលពួកទស្សនវិទូរបានធ្វើការសញ្ជឹងគិតអស់រយៈពេលយ៉ាងយូរ។ ដោយសារសំនួរទាំងនេះជាសំនួរមានសារៈសំខាន់ និងពិបាកឆ្លើយ យើងត្រូវចាត់ទុកសំនួរទាំងនេះថាជាសំនួរខាងសាសនានិងជំនឿដែលទាក់ទងទៅនឹងភាពកង្វល់នៅក្នុងអនាគតរបស់មនុស្សយើង។



ដូចសំនួរខាងលើដែរ ចំឡើយទាំងអស់ ក៏ត្រូវធ្លាក់ទៅលើក្រុមពិសេសមួយនេះដែរ។ ដោយហេតុដែលយើងជឿថា ព្រះ លោកទ្រង់ប្រទាននូវចំលើយទៅនឹងសំនួរទាំងនេះយើងក៏ចាត់ទុកចំឡើយទាំងនេះថាជា អាទិទេពវិទ្យា (theology)។ ពាក្យថា theology ឬ អាទិទេពវិទ្យា គឺបានមកពីភាសារក្រេកពីរ ដែលមានន័យថា ការសិក្សារអំពីព្រះ។ កាលណាយើងចង់ដឹងពីវត្តមានរបស់ព្រះអាទិទេព គឺយើងត្រូវធ្វើការស្វែងរកនូវសញ្ញានិងភស្តុតាងជាក់ស្តែង ដែលមាននៅជុំវិញខ្លួនយើង និងនៅក្នុងព្រះគម្ពីរ។

## B. ការសន្មត់ពីរយ៉ាងទៅលើជំនឿព្រះគ្រីស្ត



នៅពេលអ្នកប្រាជ្ញឈ្មោះ អឺយូគ្លិដ/Euclid និពន្ធសៀវភៅ រេខាគណិត/geometry គឺលោកត្រូវចាប់ផ្តើមពីទ្រឹស្តី ស្វ័យសត្យ/Axioms មានន័យថា ការសន្មតដែលមិនចេះខុស។ Axiom/ស្វ័យសត្យ គឺមិនមែនជាអ្វីដែលយើងបញ្ជាក់នោះទេ តែគឺជាអ្វីដែលយើងសន្មត់ថាជាការពិតវិញ។ បើគ្មាន Axioms/ ស្វ័យសត្យរបស់លោកអឺយូគ្លិដ នេះទេ ការសិក្សារពី geometry/ រេខាគណិត មិនអាចកើតមានបានឡើយ។ ហើយដូចគ្នានឹងឧទាហរណ៍ខាងលើនេះ សេចក្តីជំនឿរបស់អ្នកគ្រីស្ទានក៏ចាប់ផ្តើមពី Axioms/ ស្វ័យសត្យពីរយ៉ាងដែរៈ គឺចាប់ផ្តើមពីវត្តមានរបស់ព្រះអាទិទេព និងការបណ្តាលឡើងនៃព្រះនៅក្នុងព្រះគម្ពីរ (Inspiration)។ យើងមិនអាចធ្វើការបញ្ជាក់ពីចំណុចណាមួយបានទេ ប៉ុន្តែយើងសន្មត់ថាការទាំងពីរនោះគឺជាការពិត។ បើសិនជាគ្មានករណីទាំងពីរខាងលើនេះទេការសិក្សារពីជំនឿនៃអ្នកគ្រីស្ទានមិនអាចកើតមានឡើងបានឡើយ។






### សេចក្តីពិតជប់យ៉ាងអំពីព្រះគម្ពីរ



១) **ការចងក្រងព្រះគម្ពីរ:** ព្រះគម្ពីរបានចងក្រងឡើងនៅក្នុងកំឡុងពេល១៦០០ឆ្នាំដោយស្នាដៃរបស់មនុស្ស ប្រហែល៤០នាក់ គឺចាប់ផ្តើមពីឆ្នាំ១៥០០មុនរជ្ជកាលព្រះគ្រីស្ទរហូតដល់ឆ្នាំ១០០ក្រោយរជ្ជកាលព្រះគ្រីស្ទ(១៥០០ BC -១០០ AD)។

២) **ការបែងចែកព្រះគម្ពីរ:** ព្រះគម្ពីរគឺជាសៀវភៅតែមួយដែលរួមផ្សំឡើងពីសៀវភៅតូចៗចំនួន៦៦ក្បាល។ គម្ពីរបានត្រូវចែកចេញជាពីរផ្នែក សញ្ញាចាស់និងសញ្ញាថ្មី។ សញ្ញាចាស់បានចងក្រងនៅមុនរជ្ជកាលរបស់ព្រះយេស៊ូវគ្រីស្ទ ឯសញ្ញាថ្មីបានចងក្រងឡើងអំពីជីវិតរបស់ព្រះយេស៊ូវ និងព្រឹត្តិការណ៍ដែលបានកើតជាបន្តរបន្ទាប់ក្រោយការសុគតរបស់ព្រះយេស៊ូវទៅ។

៣) **ជំពូកនិងខ:** គ្រប់សៀវភៅទាំងអស់នៅក្នុងព្រះគម្ពីរលើកលែងតែសៀវភៅចំនួន៥ក្បាល ត្រូវបានបែងចែកចេញជាជំពូកនិងខ។ សៀវភៅទាំងប្រាំដែលមិនបានបែងចែកជាជំពូកមាន សៀវភៅអូបាឌា ភីលីម៉ូន យ៉ូហានទី២ យ៉ូហានទី៣ និង យូដាស។ សៀវភៅទាំងអស់នេះគឺជាសៀវភៅខ្លីៗដែលមានតែខប៉ុណ្ណោះ។ ឯជំពូកទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរបានត្រូវណែនាំមកដោយលោក ខាឌីណល់ ហ្យូហ្គោ ឌី អែស ឆ៊ែរ នៅក្នុងឆ្នាំ១២៣៨ ហើយបន្ទាប់មកខក៏ត្រូវបានបន្ថែមចូលមកក្នុងព្រះគម្ពីរនៅក្នុងឆ្នាំ១៥៥១ ដោយលោក រ៉ូបើតទិស ស្តេហ្វិនិស។









**បើលោកអ្នកចង់បានមេរៀនសិក្សារនេះជាភាសាខ្មែរ សូមទាក់ទង ឬសរសេរសំបុត្រទៅ** CAI

តទៅទំព័រទី១៤

### សំរាប់មេរៀនបន្ទាប់

1. ភាពយន្តឬសៀវភៅដែលបញ្ជាក់ប្រាប់ពីរឿងអ្វីមួយគឺយើងហៅថាសាច់រឿង។
2. ដើម្បីយល់ពីភាពយន្តឬសៀវភៅណាមួយ គឺយើងត្រូវដឹងថាតើសាច់រឿងនោះនឹងក្លាយទៅយ៉ាងដូចម្តេច។
3. ដូចឧទាហរណ៍ខាងលើនេះ ព្រះគម្ពីរថ្លែងប្រាប់យើងពីចំណាប់ផ្តើមនៃពេលវេលា និង បញ្ចប់នៅក្នុងចំណាប់ផ្តើមនៃអមតភាព។

ដើម្បីឲ្យយើងបានងាយយល់ពីរឿងនេះ គឺយើងត្រូវដឹងថា តើសាច់រឿងនេះមានការបកស្រាយយ៉ាងដូចម្តេច ក្នុងការសិក្សារជាបន្ទាប់ យើងត្រូវធ្វើការស្រាវជ្រាវទៅក្នុងសាច់រឿងនេះ។

**សេចក្តីពិតដប់យ៉ាងអំពីព្រះគម្ពីរ (ភាគបញ្ចប់)**

៧) **ពាណិជ្ជកម្មព្រះគម្ពីរ:** ព្រះគម្ពីរបានត្រូវលក់ចេញឬចែកជាអំណោយនៅក្នុងមួយថ្ងៃចំនួនជាង១៦៨០០០ក្បាល បើយោងតាមសមាគមព្រះគម្ពីរហ្គីឌីយាន្ស ហ្វាយគ្លីហ្វអន្តរជាតិ និងសមាគមព្រះគម្ពីរអន្តរជាតិ។ មតិភាគច្រើនបាននិយាយថា ព្រះគម្ពីរគឺជាសៀវភៅមួយដែលត្រូវបានលក់ចេញច្រើនជាងគេទាំងអស់នៅក្នុងពិភពលោក និងគ្រប់ពេលវេលាទាំងអស់។ ហើយដែលត្រូវបានបកប្រែជាភាសារដ៏ទៃចំនួន១២០០ ភាសារទៀតផង។

៨) **ព្រះគម្ពីរតែងគាំទ្រគ្នាជានិច្ច:** គ្មានការខ្វែងទំនាស់គ្នានៅក្នុងព្រះគម្ពីរឡើយ។ មានបុគ្គលខ្លះបានអះអាងថាគេបានរកឃើញពីការខ្វែងទំនាស់នៅក្នុងព្រះគម្ពីរ ប៉ុន្តែចំណុចនេះមិនអាចកើតមានបានឡើយលើកលែងតែគេមានការយល់ខុសអំពីអត្ថន័យឬអត្ថបទនៅក្នុងព្រះគម្ពីរ។ កាលណាអានព្រះគម្ពីរ អ្នកត្រូវមើលទៅលើរូបភាពនៅក្នុងព្រះគម្ពីរទាំងមូល ហើយខិតខំព្យាយាមយល់ដឹងនូវការបង្រៀនរបស់ព្រះគម្ពីរទៀតផង គឺបានសេចក្តីថាមិនអាចមានការខ្វែងទំនាស់នៅក្នុងព្រះគម្ពីរបានឡើយ។ នេះគឺជាការដ៏អស្ចារ្យមួយ បើគិតអំពីអាយុនៃការចងក្រងព្រះគម្ពីរ។

៩) **បទទំនាយនៃព្រះគម្ពីរ:** មានបទទំនាយចំនួនជាង៣២០០ខ ដែលបានត្រូវកើតមានឡើងដូចនៅក្នុងព្រះគម្ពីរឬចាប់តាំងពីការចងក្រងព្រះគម្ពីរមក។ ប៉ុន្តែ នៅមានចំនួនជាង៣១០០ខទៀតដែលមិនទាន់កើតមាននៅឡើយ។

១០) **អ្នកនិពន្ធព្រះគម្ពីរ:** យ៉ាងហោចណាស់មានអ្នកនិពន្ធប្រហែល៤០នាក់ចងក្រងព្រះគម្ពីរ ខ្លះជោគជ័យ ខ្លះទៀតមិនសូវជោគជ័យ។ ឯសាវកប៉ូលបាននិពន្ធសៀវភៅចំនួន១៣ក្បាល ហើយប្រហែលជានិពន្ធសៀវភៅហេព្រើរទៀតផង។ ចំណែកលោកហោរាម៉ូសេ និពន្ធសៀវភៅចំនន្ទួន៥ក្បាល គឺចាប់តាំងពីសៀវភៅដើមដំបូងនៃព្រះគម្ពីរ។

ព្រះគម្ពីរផ្តល់នូវសុភាសិតចំនួនជាង៣០០០ដល់ស្តេចសាឡូម៉ូន។ សុភាសិតទាំងអស់នោះមិនមែនមានតែនៅក្នុងសៀវភៅសុភាសិតមួយប៉ុណ្ណោះទេ ហើយភាគច្រើនស្តេចសាឡូម៉ូនទ្រង់ជាអ្នកនិពន្ធទៀតផង។



ចំណាប់ផ្តើមរបស់យើង គឺការផ្ទង់គំនិតទៅលើ Axioms/ ស្វ័យសត្យឬការសន្មតដែលមិនចេះខុស ទាំងពីរខាងលើនេះ។

ដូច្នេះគឺយើងត្រូវមើលទៅលើអត្ថន័យនៃពាក្យថា ” ព្រះអាទិទេព ” តើពាក្យនេះមានអត្ថន័យយ៉ាងដូចម្តេច? តើហេតុអ្វី បានជាអ្នកគ្រីស្ទានជឿថាមានព្រះអាទិទេពតែមួយអង្គវិញ? ហើយតើព្រះអទិទេពមានសិទ្ធិអ្វីមកបង្គាប់បញ្ជាឲ្យយើងធ្វើការរស់នៅតាមនោះ? តើធ្វើយ៉ាងដូចម្តេចដើម្បីឲ្យខ្ញុំ ដឹងថាមានព្រះអទិទេពនោះ? ហើយតើទ្រង់មានបន្ទូលមកកាន់ខ្ញុំយ៉ាងដូចម្តេច?

ចំលើយទៅនឹងសំនួរខាងលើនេះនឹងបង្ហាញយើងឲ្យឃើញនូវចំលើយពីសំនួរផ្សេងៗទៀតនៅក្នុងជីវិតរបស់យើង ហើយមិនតែប៉ុណ្ណោះ វាអាចនឹងផ្តល់ជាគ្រឹស្ថានសំរាប់ការសិក្សាររបស់យើងនូវមេរៀនក្រោយៗទៀតផងដែរ។

## វត្តមាននៃព្រះអម្ចាស់ឬព្រះអាទិទេព

### A. តើអក្សរប្រាំពាក្យនៅក្នុងព្រះគម្ពីរប្រាប់យើងអ្វីខ្លះអំពីព្រះអាទិទេព?

1. លោកុប្បត្តិ ១:១ - ***កាលដើមដំបូងឡើយ*** ***ព្រះ***បាន***បង្កើត***ផ្ទៃមេឃនិងផែនដី។

នាមទីមួយ(***ព្រះ)*** នៅក្នុងគម្ពីរ បញ្ជាក់ថា ព្រះមានតាំងពីដើមដំបូងមក។

កិរិយាសព្ទទីមួយ(***បង្កើត)*** នៅក្នុងគម្ពីរបញ្ជាក់ថា ព្រះបានបង្កើតអ្វីៗទាំងអស់។

តើហេតុអ្វីបានជាព្រះលោកបានបង្កើតសាកលលោកយើងនេះ?

យើងចង់ដឹងពីហេតុ។



យើងដឹងហើយថាគ្រប់ទាំងផលទាំងអស់គឺតែងតែកើតមកពីហេតុ



ឧទាហរណ៏: ដើមស្វាយដុះចេញពីគ្រាប់ស្វាយ (ក្នុងឃ្លានេះគ្រាប់ស្វាយគឺជាហេតុ ដើមស្វាយគឺជាផល)

គ្រាប់(ផ្លែ)ស្វាយ ចេញមកពីដើមស្វាយ (ក្នុងឃ្លានេះគ្រាប់ស្វាយជាផល ហើយដើមស្វាយជាហេតុវិញ។)

ដើមស្វាយ នៅតែបន្តរដុះចេញពីគ្រាប់(ផ្លែ)ស្វាយ ហើយ គ្រាប់(ផ្លែ)ស្វាយក៏ចេះតែបន្តរចេញមកពីដើមស្វាយ។



បើយើងចេះតែដេញចោទសួរជាច្រើនដងបន្តរទៅទៀតយើងនឹងទៅដល់ដើមស្វាយដំបូងបង្អស់។ តើដើមស្វាយដំបូងបង្អស់នោះកើតមកពីណា? យើងអាចធ្វើការសន្មតថា ដើមស្វាយដំបូងបង្អស់នោះ គឺច្បាស់ជាមានអ្នកបង្កើត គឺដូចជាការបង្កើត តុ កៅអី ឬ នាឡិកា ជាដើម។ល។ សំរេចសេចក្តីទៅ អ្វីៗដែលកើតមានឡើងនៅលើផែនដីនេះគឺតែងតែមានម្ចាស់។ ចំលើយរបស់យើងគឺថា ព្រះទ្រង់ជាអ្នកបង្កើត ផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើទាំងអស់រួមទាំងសាកលលោកទាំងមូលផងដែរ។ ដូច្នេះយើងអាចចាត់ទុកថាព្រះគឺជាបុព្វហេតុទីមួយ។

3. បន្ថែមលើនេះ ចូរយើងសំគាល់ទៅលើការអះអាងដ៏សំខាន់របស់គម្ពីរទំនុកដំកើង ៣៣:៦ ”*ដោយសារព្រះបន្ទូលរបស់ព្រះ ផ្ទៃមេឃបានកើតមក ហើយពួកតារានៅលើនោះ បានកើតដោយសារខ្យល់ពីព្រះឱស្ឋទ្រង់។*” ដូច្នេះយើងឥឡូវនេះបានដឹងថា ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី ចុះព្រះនាមនៃព្រះនេះមានឈ្មោះជាអ្វី? ព្រះនាមនៃព្រះអាទិទេពនេះឈ្មោះហៅថា ”យេហូវ៉ា ”ភាសាហេព្រើរដែលជាភាសាបុរាណបង្អស់របស់សាសន៍យូដា ឬ អ៊ីស្រាអែលបច្ចុប្បន្ននេះបញ្ជាក់ថាព្រះនាម ”យេហូវ៉ា ”គឺជានាមដ៏បរិសុទ្ធបំផុត ដូច្នេះគេមិនប្រកប ឬប្រើទេ គឺគេប្រើពាក្យថា ”អម្ចាស់ ”ជំនួសវិញ។

អ្នកប្រាជ្ញដែលបកប្រែព្រះគម្ពីរក៏បានដើរតាមទំលាប់ខាងលើនេះទៅ។



ហើយជំនួសការប្រើព្រះនាម ”យេហូវ៉ា ” គឺគេប្រើពាក្យថា ”ព្រះអម្ចាស់ ”វិញ។

អេសាយ ៤០:២៦ ”*ចូរងើយភ្នែកឯងមើលទៅឯលើហើយពិចារណា: តើអ្នកណាដែលបានបង្កើតរបស់ទាំងនេះ? ដែលនាំពួកពលបរិវារចេញមកតាមចំនួនដូច្នេះ ហើយទ្រង់ក៏ហៅតាមឈ្មោះរៀងរាល់តួ ដោយព្រះចេស្តាដ៏ធំរបស់ទ្រង់ ហើយដែលគ្មានអ្នកណាមួយខានឡើយ ដោយព្រោះតេជានុភាពដ៏ខ្លាំងក្លាដែរ។* ”



ពាក្យដែលប្រើនៅក្នុងសញ្ញាថ្មី (New Testament) គឺពាក្យ (scripture) ព្រះបន្ទូល។ អ្នកបដិវតន៍ជនជាតិអង់គ្លេសម្នាក់ឈ្មោះ ជនវ៉ាយឃ្លីហ្វ (John Wycliffe) ចាប់ផ្តើមប្រើពាក្យ ”ព្រះបន្ទូល ”ជំនួស ”ព្រះគម្ពីរ ”ជាលើកដំបូងបង្អស់ ហើយពាក្យនេះក៏ត្រូវបានប្រើជាប់ជារៀងរហូតមក។

## D. តើការបើកសំដែងនេះមានគោលបំណងអ្វី?

ទំនុកដំកើង ១១៩:១០៥ ”*ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំផង។*”

ទំនុកដំកើង ១១៩:១១ ”*ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ។*”

ម៉ាថាយ ៥:៨ ”*មានពរហើយ អស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកទាំងនោះនឹងបានឃើញព្រះ។*”

# សេចក្តីបញ្ចប់

## ចូរយើងសង្ខេបឡើងវិញ

1. យើងបានបកស្រាយនូវអត្ថន័យនៃពាក្យថា ”ព្រះ ” ឬ ”ព្រះអាទិទេព ”។
2. យើងបានដឹងថានៅក្នុងមហាសន្និវាសឬសាកលលោកនេះ គឺមានព្រះតែ១អង្គទេ ព្រះនាមយេហូវ៉ា។
3. យើងបានសិក្សាពីគន្លឹះនៃពាក្យដែលពិពណ៌នាពីលក្ខណះរបស់ព្រះ។
4. យើងបានពន្យល់នូវអត្ថន័យនៃពាក្យ:
   - ♦ វិវរណៈ ឬ ការបើកសំដែង
   - ♦ ការបណ្តាលឲ្យ ឬ ការញាំុងឲ្យ
   - ♦ ព្រះបន្ទូល

ធូលីដី
ដង្ហើមជីវិត
→ ជីវិតក៏មានឡើង

ភាសារបស់មនុស្ស
គំនិតរបស់ព្រះ
→ ពះបន្ទូលនៃព្រះ

## C. ដូច្នេះ ចុះពាក្យថាព្រះបន្ទូលមានន័យដូចម្តេច?

ព្រះបន្ទូល

↓

វិវរណៈ ឬ ការបើកសំដែង

↓

ហោរា

↓

ការបណ្តាល ឬញាំង

↓

សៀវភៅ (ព្រះគម្ពីរ)

ព្រះគម្ពីរ - ភាសាអង់គ្លេសហៅថា បាយបុល(Bible) មកពីភាសាក្រេក ប៊ីប្លីយ៉ា(biblia) មានន័យថា ”សៀវភៅតូច” ឬ ”ក្រាំងតូច”។ ពាក្យនេះចេញមកពីទំរង់ពាក្យរបស់ភាសាក្រេក ប៊ីប្លូស់(biblos) ប្រែថា ស្លឹករឹតឬក្រដាស់។ ក្រោយមកពាក្យថា ប៊ីប្លូស់ នេះក៏បានប្រែទៅជាពាក្យថា សៀវភៅឬក្រាំងវិញ។



## B. តើយើងមិនអាចមានព្រះពិតតែមួយអង្គបានទេឬ?

យេរេមា ១០:១១ *”ដូច្នេះត្រូវប្រាប់គេថា ព្រះទាំងប៉ុន្មានដែលមិនបានបង្កើតផ្ទៃមេឃនិងផែនដី នោះនឹងត្រូវវិនាសបាត់ពីផែនដីហើយពីក្រោមផ្ទៃមេឃទៅ។”*

យ៉ូហាន ១:១-៣ *”កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ... គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាននោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ។”*

អេសាយ ៣៧:១៦ *”ឱព្រះយេហូវ៉ានៃពួកពលបរិវ៉ា ជាព្រះនៃអ៊ីស្រាអែលដែលគង់នៅចន្លោះចេរ៉ូប៊ីមអើយ គឺទ្រង់តែ១ព្រះអង្គ ដែលជាព្រះនៃអស់ទាំងសាសន៍នៅផែនដី ទ្រង់បានបង្កបង្កើតផ្ទៃមេឃនិងផែនដី។”*

របាក្សត្រទី១ ១៦:២៦ *”ពីព្រោះអស់ទាំងព្រះដ៏ទៃសុទ្ធតែជារូបទទេ តែឯព្រះយេហូវ៉ាវិញ ទ្រង់បានបង្កើតផ្ទៃមេឃ។”*

នេហេមា ៩:៦ *”គឺទ្រង់តែ១ដែលជាព្រះឯកអង្គ ទ្រង់បានបង្កើតផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃ ព្រមទាំងពួកពលបរិវ៉ានៅលើនោះ ផែនដីហើយសមុទ្រ និងរបស់សព្វសារពើរដែលនៅស្ថានទាំងនោះផង ទ្រង់ក៏ផ្តល់ជីវិតដល់របស់ទាំងនោះ ហើយពួកពលនៅលើមេឃក៏ថ្វាយបង្គំដល់ទ្រង់។”*

ចូរសំគាល់ថា: សំរាប់បុគ្គលដែលជឿទៅលើព្រះតែ១អង្គ ភាសាអង់គ្លេសហៅថា (Monotheist) ឯកទិទេព។ សំរាប់បុគ្គលដែលជឿទៅលើព្រះជាច្រើនអង្គ ភាសាអង់គ្លេសហៅថា (Polytheist) ពហុទេព។ សំរាប់អ្នកគ្រីស្ទាន គឺគេមានជំនឿទៅលើព្រះតែ១អង្គគត់ដែលយើងហៅថា ឯកទិទេព។

យើងបានស្គាល់នូវមុខងាររបស់ព្រះ យើងបានស្គាល់នូវព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ យើងបានដឹងថានៅក្នុងនាទីរបស់យើង យើងបានស្គាល់នូវមុខងាររបស់ព្រះ យើងបានស្គាល់នូវព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ យើងបានដឹងថានៅក្នុងនាទីរបស់យើងជាអ្នកគ្រីស្ទាន គឺយើងត្រូវជឿទៅលើព្រះតែ១អង្គគត់ ដូច្នេះបន្ទាប់មកទៀត គឺយើងត្រូវដឹងថាតើព្រះលោកមានលក្ខណភាពដូម្តេច?

## C. តើព្រះដែលជាអម្ចាស់មានលក្ខណៈដូចម្តេច?

យ៉ូហានទី១ ៤:៨ *"អ្នកណាដែលគ្មានសេចក្តីស្រឡាញ់នោះមិនស្គាល់ព្រះទេ ពីព្រោះទ្រង់ជាសេចក្តីស្រឡាញ់។"*

ដូច្នេះយើងដឹងថា លក្ខណភាពរបស់ព្រះ គឺទ្រង់ជាសេចក្តីស្រឡាញ់។ ហើយ តើសេចក្តីស្រឡាញ់នោះគឺជាអ្វី?

កូរិនថូសទី១ ១៣:៤-៦ *"ឯសេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្តីស្មោះត្រង់វិញ។"*

ទាំងអស់នេះហើយ គឺជាលក្ខណភាពរបស់ព្រះអាទិទេព។

| សេចក្តីស្រឡាញ់ | ព្រះទ្រង់ |
|---|---|
| គឺជាការការអត់ធ្មត់ | ជាសេចក្តីអត់ធ្មត់ |
| គឺជាសេចក្តីសប្បុរស | ជាសេចក្តីសប្បុរស |
| មិនចេះឈ្នានីស | មិនចេះឈ្នានីស |
| មិនចេះអួតខ្លួន | មិនចេះអួតខ្លួន |
| មិនដែលមានចិត្តធំ | មិនដែលមានចិត្តធំ |
| មិនដែលប្រព្រឹត្តបែបមិនគួរសម | មិនដែលប្រព្រឹត្តបែបមិនគួរសម |
| មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន | មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន |
| មិនរហ័សខឹង | មិនរហ័សខឹង |
| មិនប្រកាន់ទោស | មិនប្រកាន់ទោស |
| មិនអរសប្បាយចំពោះសេចក្តីទុច្ចរិត | មិនអរសប្បាយចំពោះសេចក្តីទុច្ចរិត |
| អរសប្បាយតែនឹងសេចក្តីស្មោះត្រង់ | អរសប្បាយតែនឹងសេចក្តីស្មោះត្រង់ |

តើយ៉ាងដូចម្តេចបានជាយើងអាចដឹងនូវសេចក្តីខាងលើទាំងអស់នេះ? ចំលើយយ៉ាងខ្លីគឺថា ព្រះនឹងបើកសំដែងឲ្យយើងឃើញ។ មនុស្សលោកយើងនៅគ្រប់ជំនាន់ ខិតខំរុករកស្រាវជ្រាវតាមមធ្យោបាយផ្សេងៗ បច្ចេកទេសទំនើបៗ ដោយប្រើគ្រឿងកំព្យូទ័រដែលមានល្បឿនលឿនបំផុត ក៏មិនអាចស្វែងរកឃើញនូវសេចក្តីពិតរបស់ព្រះអាទិទេពរបស់យើងបានដែរ គឺលើកលែងតែទ្រង់បានបើកសំដែងឲ្យយើងឃើញប៉ុណ្ណោះ។



# ការបើកសំដែងរបស់ព្រះ

## A. តើព្រះលោកបើកបង្ហាញរូបអង្គទ្រង់យ៉ាងដូចម្តេច?

វិវរណៈ ១:១ *"នេះជាសេចក្តីដែលព្រះយេស៊ូវគ្រីស្ទបានបើកឲ្យឃើញ ជាសេចក្តីដែលព្រះបានប្រទានមកទ្រង់ ដើម្បីនឹងបង្ហាញដល់ពួកបាវបំរើទ្រង់ឲ្យដឹងពីអស់ទាំងការដែលបន្តិចទៀតត្រូវកើតមានមក ទ្រង់ក៏បានសំដែងឲ្យឃើញដោយចាត់ទេវតាទ្រង់មកឯយ៉ូហានជាបាវបំរើទ្រង់។"*

វិវរណៈ ១:១១ *"ការអ្វីដែលឯងឃើញ នោះចូរកត់ទុកក្នុងសៀវភៅចុះរួចផ្ញើរទៅឯពួកជំនុំទាំង៧។"*




## B. តើពាក្យអ្វីដែលពិពណ៌នាពីសេចក្តីដែលព្រះបានប្រទានមកនេះ?

ធីម៉ូថេទី២ ៣:១៦ "គ្រប់បទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ។

លោកុប្បត្តិ ២:៧ *"ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់យកធូលីដីមកសូន្យធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះមនុស្សក៏ត្រឡប់ជាមានជីវិតរស់ឡើង។"*